# របាយការណ៍ចុះបេសកកម្ម

## លើបញ្ហាអ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍



## ថ្ងៃទី១៩~២០ ខែកក្កដា ឆ្នាំ២០១៦

## ខេត្តកោះកុង

កាលពីថ្ងៃទី១៩-២០ ខែកក្កដា ឆ្នាំ២០១៦ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តមអគ្គលេខាធិការ រួមដំណើរដោយមន្ត្រីបច្ចេកទេស បានចុះបេសកកម្ម ពិនិត្យមើលបញ្ហាអ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ក្នុងខេត្តកោះកុង និងការអនុវត្តគោលនយោបាយ ៧ចំណុច របស់រាជរដ្ឋាភិបាល ទៅតាមកម្មវិធីដែលបានគ្រោងទុកៈ

## ១-ការចុះពិនិត្យ និងស្វែងយល់ស្ថានភាពអេដស៍នៅមន្ទីរពេទ្យខេត្ត

- នៅក្នុងត្រីមាសទី១ដើមឆ្នាំ២០១៦នេះ អ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ មានរហូតដល់ ៩៥នាក់ ដែលមកទទួលថ្នាំពន្យាជីវិត ក្នុងនោះ មានចំនួន ៧៥ នាក់ មកពីប្រទេសថៃ ។
- អ្នកជំងឺថ្មីមានចំនួន ២៣នាក់ ប្រុស ១០ នាក់ និងស្រី ១៣នាក់(ដែលមានអាយុពី១៥ ដល់៤៥ឆ្នាំ ) ។
- បញ្ហាលំបាក: ដោយមិនមានប្រាក់ឧបត្ថម្ភ មិនមានបុគ្គលិកធ្វើការងារសម្រាប់តែទទួលអ្នកជំងឺអេដស៍ទេ មន្ទីរពេទ្យបានរៀបចំពិនិត្យអ្នកជំងឺអេដស៍ ត្រូវធ្វើតែនៅពេលល្ងាច ដូច្នេះបុគ្គលិកនិងគ្រូពេទ្យដែលត្រូវយាមប្រចាំការត្រូវមកធ្វើកិច្ចការនេះ ។



## ២-ការចុះពិនិត្យមើលអ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងពន្ធនាគារ

ដោយមានការសម្របសម្រួលពីអ្នកស្ម័គ្រចិត្ត (CPN+) និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ក្រុមបេសកកម្ម បានជួបជាមួយអ្នករស់នៅជាមួយមេរោគអេដស៍ជាទណ្ឌិត និងមន្ត្រីប៉ូលីសដែលធ្វើការផ្នែកសុខាភិបាលនៅក្នុងពន្ធនាគារ ព័ត៌មានដែលយើងទទួលបាន៖

- មានអ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ចំនួន ១៣នាក់ ស្រី០២ នាក់ ដែលស្ថិតនៅក្នុងពន្ធនាគារ ។
- បញ្ហាប្រឈមអ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ទាំងអស់នោះ ពុំមានថវិកាសម្រាប់ធ្វើដំណើរទៅទទួលសេវាថ្នាំពន្យាជីវិត។ កន្លងមក អង្គការថែរក្សាសុខភាពជាអ្នកគាំទ្រលើសេវានេះ ហើយបច្ចុប្បន្នអង្គការថែរក្សាសុខភាពផុតគម្រោង។
- នៅមានអ្នកដែលបន្តការរួមភេទដោយមិនប្រើស្រោមអនាម័យ បើទោះបីដឹងថាខ្លួនមានផ្ទុកមេរោគអេដស៍ក៏ដោយ ។

**ជាលទ្ធផល**

- បានពន្យល់ពីការចម្លងដោយចេតនានៅពេលដែលដឹងថាខ្លួនមានផ្ទុកមេរោគអេដស៍
- ពន្យល់ ដើម្បីកែតម្រូវការយល់ច្រឡំពីការបញ្ចប់អេដស៍នៅឆ្នាំ២០៣០



### ៣-ចុះពិនិត្យមើលអ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងសង្កាត់ស្មឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង

ក្រុមបេសកកម្ម បានជួបជាមួយក្រុមស្ម័គ្រចិត្តធ្វើការអប់រំផ្ទាល់នៅតាមគ្រឹះស្ថានកម្សាន្តសប្បាយ អ្នករស់នៅជាមួយមេរោគអេដស៍ និងមន្ត្រីកម្មវិធីអេដស៍ខេត្ត ៖

- ចុះពិនិត្យដល់ផ្ទះគ្រួសារដែលមានផ្ទុកមេរោគអេដស៍បីគ្រួសារ ដែលមានទីតាំងនៅភូមិផ្សេងៗគ្នា ។ ជាទូទៅ គាត់បានទទួលថ្នាំពន្យាជីវិតជាទៀងទាត់តាមការកំណត់។
- ដោយស្ថានភាពក្រីក្រពេក ពួកគាត់នឹងប្រឈមការខ្វះថវិកាធ្វើដំណើរនៅពេលឆាប់ៗខាងមុខនេះ។
- ការគ្មានថវិកាសម្រាប់ធ្វើដំណើរទៅទទួលសេវាថ្នាំពន្យាជីវិត ដែលអាចប្រឈមនឹងការប្រើប្រាស់មិនត្រឹមត្រូវ ។
- ស្នើសុំអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីទទួលបានប័ណ្ណសមធម៌




### ៤- ការជួបប្រជុំពិភាក្សាជាមួយគណៈកម្មាធិការ និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តៈ

ក្រុមបេសកកម្ម បានជួបប្រជុំជាមួយលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត និងសមាជិកសំខាន់ៗ ដែលមានប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានមន្ទីរសុខាភិបាលខេត្ត អនុប្រធានមន្ទីរសុខាភិបាលខេត្ត និងមន្ត្រីកម្មវិធីអេដស៍ខេត្ត និងមានការចូលរួមពីអង្គការសង្គមស៊ីវិល និងបណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍ កិច្ចពិភាក្សា បានផ្តោតទៅលើចំណុចប្រឈមមួយចំនួន ដូចខាងក្រោម ៖

- នៅក្នុងត្រីមាសទី២ អ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍មានចំនួន ៨៨០នាក់ ហើយបច្ចុប្បន្នកំពុងទទួលថ្នាំពន្យាជីវិត ។

- មានអង្គការសង្គមស៊ីវិលចំនួន០៣ ដែលធ្វើការងារអេដស៍ មានអង្គការ CWPD MHC និងបណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍(CPN+) ។
- នៅក្នុងសង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានអ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ចំនួន ៥៦នាក់ ប្រុស២២នាក់ និងស្រី២៨នាក់ ដែលជួបបញ្ហាខ្វះថវិកាសម្រាប់ធ្វើដំណើរទៅទទួលសេវាថ្នាំពន្យាជីវិត ។ ដោយកន្លងមក មានអង្គការថែរក្សាសុខភាព ជាអ្នកគាំទ្រ តែបច្ចុប្បន្នអស់គម្រោង ។
- ការអនុវត្តន៍គោលនយោបាយ៧ចំណុចរបស់រាជរដ្ឋាភិបាល: នៅពុំទាន់មានកម្មវិធីផ្សព្វផ្សាយទៅលើយុវជនដែលកំពុងសិក្សានៅតាមបណ្តាសកលវិទ្យាល័យ និងគ្រឹះស្ថានសិក្សានានា នៅក្នុងខេត្តកោះកុង ។
- ការជួយគាំទ្រពីអាជ្ញាធរដែនដី អភិបាលក្រុង មានលក្ខណៈល្អក្នុងការផ្សព្វផ្សាយក្នុងគ្រឹះស្ថានកំសាន្តសប្បាយ ។



ក្រោយពីការពិភាក្សារួចមក ឯកឧត្តមអគ្គលេខាធិការក៏បានផ្តល់ការណែនាំដូចតទៅ ៖

- ត្រូវពង្រឹងនូវការចុះធ្វើការអប់រំផ្ទាល់ និងផ្សព្វផ្សាយបន្ថែមដល់ស្ត្រីបម្រើសេវានៅតាមគ្រឹះស្ថានកម្សាន្តសប្បាយ និងកាស៊ីណូដែលមិនទាន់មាន ដោយទំនាក់ទំនងនឹងមន្ទីរការងារ ។

- ត្រូវបង្កើតកម្មវិធីចុះអប់រំផ្សព្វផ្សាយដល់យុវជននៅតាមគ្រឹះស្ថានសិក្សានានានៅក្នុងខេត្តកោះកុង ដោយទំនាក់ទំនងជាមួយមន្ទីរអប់រំ យុវជន និងកីឡា និងយុវជនកាកបាទក្រហមកម្ពុជា និងកាយរិទ្ធ។
- ស្នើសុំឲ្យអង្គការសង្គមស៊ីវិលដែលធ្វើការងារអេដស៍ បើចុះទៅធ្វើការនៅកន្លែងណាមួយ ហើយមានបញ្ហា ត្រូវប្រញាប់រាយការណ៍មកមន្ទីរសុខាភិបាល ដែលជាប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ ឬគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ដើម្បីជួយសម្របសម្រួល។
- បង្កើនការសម្របសម្រួល និងចូលរួមពីអាជ្ញាធរដែនដី សមត្ថកិច្ច បន្ថែមទៀត។
- អង្គភាពថវិការបស់មន្ទីរពេទ្យស្រុកប្រតិបត្តិ ត្រូវប្រមើលមើលលើតម្រូវការថវិកាសម្រាប់បំពេញចំណុចខ្វះចន្លោះនៃការងារអេដស៍ ដែលគន្លងមកគាំទ្រដោយជំនួយពីខាងក្រៅ ។

៨- សេចក្តីសន្និដ្ឋានៈ

- ជាទូទៅការផ្តល់សេវាបង្ការ និងថែទាំ អនុវត្តបានល្អចំពោះអ្នករស់នៅជាមួយមេរោគអេដស៍ និងស្ត្រីបម្រើនៅតាមគ្រឹះស្ថានសេវាកម្សាន្តសប្បាយ និងកាស៊ីណូ ។
- ការអនុវត្តគោលនយោបាយ៧ចំណុច នៅមានការកង្វះខាតដោយពុំមានកម្មវិធីផ្សព្វផ្សាយទៅលើយុវជន ដែលកំពុងសិក្សានៅតាមបណ្តាសកលវិទ្យាល័យ និងកាស៊ីណូ។
- ចំពោះគ្រួសារដែលរស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ ស្នើសុំអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីទទួលបានប័ណ្ណសមធម៌ ។
- បញ្ហាថវិកានៅតែជាបញ្ហាចំបង ។

ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការ**

**ឯកឧត្តមវេជ្ជ តែង គន្ធី**